# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាស្តីពីកិច្ចប្រជុំលើកទី ៥២ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២១

នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០២១ គណៈកម្មាធិការប្រឹក្សាគម្រោង (PAC) នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) បានប្រារព្ធកិច្ចប្រជុំរបស់គណៈកម្មការប្រឹក្សា ។ គណៈកម្មាធិការប្រឹក្សាគម្រោងBFC (PAC) ដែលរួមមានសមាសភាពមកពី តំណាងរាជរដ្ឋាភិបាលកម្ពុជា (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម) តំណាងនិយោជក (សមាគមរោងចក្រកាត់ដេរនៅកម្ពុជា - GMAC) និងតំណាងកម្មករនិយោជិត (តំណាងមកពីសហភាព និងសហព័ន្ធសហជីពផ្សេងៗគ្នា)។

ក្នុងឆ្នាំនេះ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងដៃគូពាក់ពន្ធបានប្រារព្ធខួបលើកទី 20 របស់គម្រោងBFC។ គម្រោងនេះបានផ្សារភ្ជាប់ការធ្វើពាណិជ្ជកម្មជាមួយស្តង់ដារការងារក្នុងវិស័យកាត់ដេរនិង វាយនភណ្ឌនៅកម្ពុជា ដើម្បីលើកកម្ពស់ការអនុលោមតាមច្បាប់ និងជម្រុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ការងារដែលមានស្រាប់ និងដើម្បីលើកកម្ពស់សិទ្ធិការងារឲ្យស្របជាមួយ នឹងច្បាប់ការងារជាតិ និងស្តង់ដារពលកម្ម ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ វិធីសាស្ត្ររបស់កម្មវិធីរួមមានការបណ្តុះកិច្ចសន្ទនាសង្គម តាមរយៈគណៈកម្មការដែលមានថ្នាក់គ្រប់គ្រងនិងកម្មករ ការផ្តល់សេវាកម្មប្រឹក្សាយោបល់ដល់រោងចក្រដើម្បីជួយពួកគេដោះស្រាយបញ្ហាប្រឈមផ្នែកច្បាប់ការងារ ឬប្រើរបាយការណ៍សាធារណៈដើម្បីជំរុញឱ្យមានភាពប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារក្នុងរោងចក្រនិងបរិយាកាសការងារនៅក្នុងវិស័យឧស្សាហកម្មទាំងមូល។

1. យើងខ្ញុំទាំងអស់គ្នាដែលជាសមាជិកគណៈកម្មការប្រឹក្សាគម្រោង (PAC) នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងរួមគ្នានិងសមិទ្ធិផលដែលទទួលបានពីការធ្វើការរួមគ្នាជាមួយ BFCក្នុងកំឡុងពេលដែលមានជំងឺរាតត្បាតកូវីដ-១៩ ដែលបានគាំទ្រដល់វិស័យកាត់ដេរក្នុងគ្រាលំបាកនេះ ហើយយើងប្តេជ្ញានៅតែបន្តគាំទ្រគម្រោងBFC ក្នុងការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនៃវិស័យឧស្សាហកម្មនេះ និងសូមអបអរសាទរ ខួបលើកទី 20 របស់ BFC។ រួមគ្នា យើងសម្រេចបាននូវភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងវិស័យឧស្សាហកម្មក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។

2. PAC ប្តេជ្ញាចិត្តក្នុងការអនុវត្តវិធានការការពារជំងឺកូវីដ-១៩នៅក្នុងវិស័យកាត់ដេរ និងធ្វើការរួមគ្នាដើម្បីស្តារឡើងវិញនូវផលប៉ះពាល់នានាដែលកើតមានដោយសារជំងឺរាតត្បាតនេះ។ យើងប្តេជ្ញាគាំទ្រឲ្យមាននូវបរិយាកាសមួយដែល និយោជិក និងតំណាងកម្មករអាចបង្កើនការដោះស្រាយបញ្ហាតាមរយៈកិច្ចសន្ទនាសង្គមប្រកបដោយប្រសិទ្ធភាពនិងភាពចាស់ទុំ។
3. យើងទទួលស្គាល់ថាយើងបានរួមគ្នាទទួលខុសត្រូវក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែងនៃវិស័យឧស្សាហកម្មកម្ពុជា។ ហើយយើងនឹងបន្តចូលរួមជាមួយអ្នកពាក់ព័ន្ធក្នុងឧស្សាហកម្ម រួមទាំងក្រុមហ៊ុនផលិត និងអ្នកបញ្ជាទិញ ដើម្បីឲ្យមានការកែលម្អជាបន្តបន្ទាប់។ ក្នុងឆ្នាំបន្ទាប់យើង នឹងរួមបញ្ចូលការលើកកម្ពស់ប្រាក់ឈ្នួលឌីជីថលនៅក្នុងឧស្សាហកម្ម ដោយទទួលស្គាល់ថាយើងត្រូវការពេលវេលាគ្រប់គ្រាន់ សម្រាប់ការលើកកម្ពស់ការយល់ដឹងពីប្រាក់ឈ្នួលឌីជីថល ការទប់ស្កាត់អំពើហិង្សា និងការបៀតបៀនយេនឌ័រនៅក្នុងរោងចក្រ និងធ្វើការលើការត្រៀមខ្លួនសម្រាប់ឧស្សាហកម្ម ៤.0 នៃឧស្សាហកម្មកាត់ដេរកម្ពុជា។ យើងក៏ទទួលស្គាល់ពីសារៈសំខាន់នៃការបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពការងារ និងសុខភាពនៅក្នុងឧស្សាហកម្មនេះ។ សម្រាប់ដំណាក់កាលយុទ្ធសាស្ត្របន្ទាប់ យើងសូមណែនាំគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ឱ្យផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការអភិវឌ្ឍន៍ជំនាញ។
4. ក្នុងពេលដែលយើងចាប់ផ្តើមសហការកាន់តែច្រើនជាមួយនឹងរោងចក្រទំនិញធ្វើដំណើរ និងកាបូប យើងប្តេជ្ញារួមចំណែកក្នុងការធានាសិទ្ធិការងារ និងលក្ខខណ្ឌការងារប្រកបដោយចីរភាពនៅក្នុងវិស័យនេះ។ **យើងសូមអំពាវនាវឱ្យរោងចក្រទំនិញធ្វើដំណើរ និងកាបូបទាំងអស់នៅក្នុងប្រទេសកម្ពុជា ចុះឈ្មោះជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) ក្រោមសេវាកម្មការត្រួតពិនិត្យលក្ខខណ្ឌការងារ (ប្រកាសអន្តរក្រសួងលេខ ៣៦៤/២០)។**
5. យើងសូមសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តក្នុងការបន្តធ្វើការជាដៃគូជាមួយ អង្គការអន្តរជាតិខាងការងារ (ILO) ដែលក្នុងទសវត្សចុងក្រោយនេះបានផ្លាស់ប្តូរវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជារួមទាំងលក្ខខណ្ឌការងារ និងជីវិតរបស់កម្មករកាត់ដេរកម្ពុជារាប់លាននាក់និងក្រុមគ្រួសាររបស់ពួកគេ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១